January 16, 2019

# បញ្ហារបស់លោក កឹម សុខា នឹងត្រូវលើកឡើងនៅក្នុងដំណើរទស្សនកិច្ចរបស់ឧបការីរងការពារជាតិអាមេរិកនៅកម្ពុជា



លោក Dr. Joseph H. Felter ឧបការីរងក្រសួងការពារជាតិអាមេរិកសម្រាប់តំបន់អាស៊ីអាគ្នេយ៍ @RFI

ដោយ វ៉ា សំណាព្ rfi 15/01/2019

ឧបការីរងក្រសួងការពារជាតិអាមេរិកសម្រាប់តំបន់អាស៊ីអាគ្នេយ៍លោក Dr. Joseph H. Felter កំពុងបំពេញទស្សនៈកិច្ចរយៈពេល២ថ្ងៃនៅកម្ពុជា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការយោធារវាងប្រទេសទាំងពីរ។ នៅក្នុងដំណើរទស្សនកិច្ចនេះ បញ្ហារបស់លោក កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិក៏ត្រូវបានលើកឡើងផងដែរ។

យោងតាមសេចក្តីប្រកាសព័ត៌មានខ្លីរបស់ស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា លោក Dr. Joseph H. Felter បានចាប់ផ្តើមបំពេញទស្សនកិច្ចរបស់លោកនៅកម្ពុជា ចាប់ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ១៦ មករា ឆ្នាំ ២០១៩ នេះតទៅ។ នៅក្នុង

ដំណើរទស្សនកិច្ចនេះ លោកនឹងជួបជាមួយមន្ត្រីជាន់ខ្ពស់យោធាកម្ពុជា លោកនាយឧត្តមសេនីយ៍ នាង ផាត រដ្ឋលេខាធិការក្រសួងការពារជាតិកម្ពុជា ដោយផ្តោតលើការផ្លាស់ប្តូរយោបល់គ្នា ជុំវិញការបើកទូលាយនិងសេរីនៅក្នុងតំបន់ Indo-Pacific។

សេចក្តីប្រកាសព័ត៌មានខ្ញីនេះឲ្យដឹងបន្ថែមថា លោក Joseph H. Felter ក៏នឹងពិភាក្សាពីរបៀបនៃការពង្រឹងកិច្ចសហប្រតិបត្តិការយោធារវាងប្រទេសទាំងពីរផងដែរ ស្របពេលដែលរដ្ឋាភិបាលកម្ពុជា កំពុងពង្រឹងច្បាប់ រួមទាំងការខិតខំធ្វើកំណែទម្រង់ផ្សេងៗទៀត។ នៅក្នុងដំណើរទស្សនកិច្ចនេះ លោក Joseph H. Felter ក៏នឹងពិនិត្យមើលលើការរីកចំរើននៃការទម្លាក់ចោលការចោទប្រកាន់ទាំងអស់លើលោក កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិ សេរីភាពសារព័ត៌មាន និងអង្គការសង្គមស៊ីវិលនៅកម្ពុជាផងដែរ។

គួរជំរាបជូនថា នេះគឺជាដំណើរទស្សនកិច្ចលើកទី១ របស់មន្ត្រីជាន់ខ្ពស់យោធាអាមេរិកនៅកម្ពុជា សម្រាប់ឆ្នាំ២០១៩នេះ បន្ទាប់ពីសហរដ្ឋអាមេរិកកំពុងត្រៀមដោះដូរឯកអគ្គរដ្ឋទូតថ្មីប្រចាំនៅកម្ពុជា និងស្របពេលដែលទំនាក់ទំនងរវាងកម្ពុជានិងអាមេរិក ហាក់មានគម្លាតពីគ្នាកាន់តែឆ្ងាយទៅៗ។

កាលពីថ្ងៃទី ១៨ មករា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានខ្លាំងៗ ពីការដាក់គំនាប់កាន់តែខ្លាំងលើអតីតគណបក្សប្រឆាំងនៅកម្ពុជា ប្រសិនបើសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ដាក់ទណ្ឌកម្មសេដ្ឋកិច្ចមកលើកម្ពុជា៕